Save the Children | Helen Keller INTERNATIONAL | unicef | World Health Organization | World Vision

# ខែ ឧសភា ឆ្នាំ ២០១៤

# សេចក្តីថ្លែងការណ៍រួមអំពីផលិតផលជំនួសទឹកដោះម្តាយក្នុងប្រទេសកម្ពុជា

ការសិក្សានាពេលថ្មីៗមួយអំពីការខាតបង់ផ្នែកសេដ្ឋកិច្ច ដោយសារបញ្ហាកង្វះអាហារូបត្ថម្ភនៅកម្ពុជា បានគូសបញ្ជាក់ឲ្យឃើញថា កុមារមានអាយុក្រោម៦ខែ ប្រមាណ១,៣៨៧នាក់បានស្លាប់ជារៀងរាល់ឆ្នាំ ដែលបណ្តាលមកពីការអនុវត្តការបំបៅកូនដោយទឹកដោះម្តាយមិនបានល្អត្រឹមត្រូវ ដែលចំនួននេះប្រហែលជាស្មើនឹង ១០% នៃករណីស្លាប់ទាំងអស់របស់កុមារអាយុក្រោម៦ខែ។

បើទោះបីជាកម្ពុជាបានធ្វើឲ្យមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់លើការកាត់បន្ថយអត្រាមរណភាពកុមារចាប់តាំងពីឆ្នាំ២០០០មកក៏ដោយ ប៉ុន្តែកុមារកម្ពុជារហូតដល់ទៅ៤០% នៅមានបញ្ហាកង្វះអាហារូបត្ថម្ភ ខណៈដែលកំណើននៃការផ្សព្វផ្សាយ និង ការប្រើប្រាស់ផលិតផលជំនួសទឹកដោះម្តាយក្នុងប្រទេសកម្ពុជា កំពុងតែមានការកើនឡើងគួរឱ្យព្រួយបារម្ភ។ ការប្រើប្រាស់ទឹកដោះគោម្សៅផ្សំតាមរូបមន្តសម្រាប់ចិញ្ចឹមទារក និងផលិតផលជំនួសទឹកដោះម្តាយដទៃទៀត មិនត្រឹមតែរារាំងដល់ការរីកចំរើនបន្តទៀតលើបញ្ហាកង្វះអាហារូបត្ថម្ភប៉ុណ្ណោះទេ ប៉ុន្តែវាអាចធ្វើឱ្យវឌ្ឍនភាពដែលសម្រេចបានតាមរយៈការបំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់ និងការបន្តបំបៅដោះកូន (ដែលអត្រាបានកើនឡើងពី ១១% ទៅ ៧៤% នៅចន្លោះឆ្នាំ២០០០ និង ឆ្នាំ២០១០) មានការធ្លាក់ចុះមកវិញ។ លើសពីនេះទៅទៀត បញ្ហានេះអាចគំរាមកំហែងចំពោះវឌ្ឍនភាពដែលសម្រេចបានទាក់ទងទៅនឹងការកាត់បន្ថយអត្រាមរណភាពរបស់កុមារផងដែរ។

សេដ្ឋកិច្ចដែលកំពុងតែអភិវឌ្ឍន៍ដូចនៅក្នុងប្រទេសកម្ពុជា គឺជាប្រភពមួយដ៏សំខាន់នៃកំណើនប្រាក់ចំណូលរបស់ឧស្សាហកម្មនៃផលិតផលជំនួសទឹកដោះម្តាយ ហើយឥទ្ធិពលរបស់ក្រុមហ៊ុនផលិតផលជំនួសទឹកដោះម្តាយមកពីបរទេសក៏កំពុងតែមានការកើនឡើងដែរ។ លទ្ធផលបឋមនៃការស្រាវជ្រាវដែលបានធ្វើឡើងនៅរាជធានីភ្នំពេញ បង្ហាញឱ្យឃើញថាមានផលិតផលជំនួសទឹកដោះម្តាយយ៉ាងច្រើនគួរឱ្យភ្ញាក់ផ្អើលរហូតដល់ទៅ១១៣ប្រភេទខុសៗគ្នាដាក់លក់នៅលើទីផ្សារ។ កំណើននៃចំនួនផលិតផលហើយងាយស្រួលស្វែងរកទាំងអស់នេះ រួមជាមួយកំណើននៃការផ្សព្វផ្សាយលក់ និងការធ្វើទីផ្សារផលិតផល អាចធ្វើឱ្យព័ត៌មានអំពីអាហារូបត្ថម្ភល្អ និងការអនុវត្តន៍ល្អត្រូវបានចុះខ្សោយ។ ការអង្កេតមួយនាពេលថ្មីៗនេះទៅលើម្តាយដែលមានកូនអាយុក្រោម២ឆ្នាំបានបង្ហាញថា ម្តាយចំនួន៨៦% បានឃើញ លឺ ឬ អានការផ្សព្វផ្សាយពាណិជ្ជកម្មអំពីផលិតផលជំនួសទឹកដោះម្តាយ ចាប់តាំងពីកូនរបស់ពួកគាត់កើត។

ការវិភាគបន្ថែមដ៏ស៊ីជម្រៅមួយទៅលើការអង្កេតប្រជាសាស្ត្រ និងសុខភាពនៅកម្ពុជាឆ្នាំ២០១០ បានបង្ហាញថា ការប្រើប្រាស់ផលិតផលជំនួសទឹកដោះម្តាយ នៅតំបន់ទីក្រុង និង នៅតាមមូលដ្ឋានសុខភាពឯកជន ក៏កំពុងមានការកើនឡើងផងដែរ។ កុមារ១នាក់ ក្នុងចំណោមកុមារ៥នាក់នៅតំបន់ទីក្រុង ឬ នៅក្នុងគ្រួសារដែលមានកម្រិតទ្រព្យធនខ្ពស់បំផុត គឺប្រើប្រាស់ផលិតផលជំនួសទឹកដោះម្តាយដើម្បីចិញ្ចឹមកូន និង ស្ត្រី១នាក់ ក្នុងចំណោមស្ត្រី៤នាក់ ដែលសម្រាលកូននៅគ្លីនិកឯកជន ប្រើប្រាស់ទឹកដោះគោម្សៅផ្សំតាមរូបមន្តសម្រាប់ចិញ្ចឹមទារក ដែលចំនួននេះមានកម្រិតខ្ពស់ជាងស្ត្រីដែលសម្រាលកូននៅតាមមន្ទីរពេទ្យរដ្ឋរហូតដល់ទៅ៣ដង។ វាពិតជាមានសារៈសំខាន់ខ្លាំងណាស់ដែលត្រូវផ្តល់ព័ត៌មានត្រឹម